# មេរៀនទី ៤៣: យ៉ាកុបរៀបការជាមួយលេអា និង រ៉ាជែល

## លោកុប្បត្តិ ២៩:១៥-៣០

**គោលបំណង៖** ព្រះធ្វើការនៅគ្រប់ស្ថានភាពទាំងអស់។

**ខគម្ពីរចងចាំ៖** រ៉ូម ៨:២៨ *"តែយើងដឹងថា គ្រប់ការទាំងអស់ផ្សំគ្នាសំរាប់សេចក្ដីល្អដល់ពួកអ្នកដែលស្រឡាញ់ព្រះគឺដល់ពួកអ្នកដែលទ្រង់ហៅមក តាមព្រះដំរិះទ្រង់។"*

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្ដើមបង្រៀន)**

តើអ្នកកំពុងតែប្រឈមមុខនឹងបញ្ហា ឬការលំបាកមែនឬទេ? តើអ្នកនឹងឆ្លើយតបបែបណាចំពោះការលំបាកនោះ ដើម្បីឱ្យអ្នកអាចផ្លាស់ប្រែនិងពង្រឹងនូវសេចក្តីជំនឿរបស់អ្នកបាន? បើសិនជាអ្នកកំពុងតែស្ថិតនៅក្នុងស្ថានភាពដ៏លំបាក សូមប្រាប់រឿងរ៉ាវរបស់អ្នកទៅកាន់មនុស្សដែលអ្នកទុកចិត្ត ហើយអនុញ្ញាតឱ្យម្នាក់នោះលើកទឹកចិត្តអ្នក។ មនុស្សគ្រប់គ្នាសុទ្ធតែជួបនឹងការលំបាកក្នុងជីវិត តែសូមឱ្យអ្នកបានកំសាន្តចិត្តហើយដឹងថាព្រះប្រើការលំបាករបស់យើងដើម្បីជួយយើងឱ្យរីកចំរើន ហើយធ្វើឱ្យយើងកាន់តែដូចជាព្រះយេស៊ូវ។

**ចំរៀង៖** ១. ព្រះអង្គនៃយើងទ្រង់ខ្លាំងពូកែ ២.ព្រះយើងជាព្រះអស្ចារ្យ ៣. ខ្ញុំថ្វាយបង្គំទ្រង់

**១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបើក)*

**២. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**៣. ល្បែងកំសាន្ត** **« ការល្អកើតចេញពីការអាក្រក់ »**

**សំភារៈដែលត្រូវការមាន៖** ថាស១ ដុំថ្ម ខ្សាច់ និងទឹក




- ថាស៖ តំណាងឱ្យជីវិត
- ថ្ម ៖ តំណាងឱ្យការទុកចិត្តលើព្រះ
- ខ្សាច់ ៖ តំណាងឱ្យការមិនទុកចិត្តព្រះ
- ទឹក ៖ តំណាងឱ្យរឿងអាក្រក់ដែលអាចកើតមានចំពោះយើង

**គ្រូសួរសំណួរថា** " តើមានការអាក្រក់ណាខ្លះដែលអាចកើតមានចំពោះយើង?" *(ចំលើយអាចជា៖ឪពុកម្ដាយឈ្លោះគ្នា ឬពេលប្រលែងគ្នាមិត្តភក្តិធ្វើឱ្យប្អូនមានរបួស)*

- នៅក្នុងថាស ដាក់ថ្មនៅផ្នែកម្ខាង ហើយម្ខាងទៀតដាក់ខ្សាច់

តើប្អូននឹងពឹងផ្អែកលើអ្វីនៅពេលដែលមានរឿងអាក្រក់កើតឡើងចំពោះប្អូន? (គ្រូនឹងចាក់ទឹកលើគំនរខ្សាច់ហើយបន្ទាប់មកចាក់ទឹកលើថ្ម) តើមានអ្វីកើតឡើងចំពោះខ្សាច់ និងថ្មនៅពេលដែលយើងចាក់ទឹកលើវា (រឿងអាក្រក់នៅក្នុងជីវិត)? ខ្សាច់រាយប៉ាយគ្រប់កន្លែងតែថ្មអត់រង្គើទៅណាទេ! នៅពេលដែលយើងនៅជាមួយព្រះយេស៊ូវយើងអាចរឹងមាំដូចជាថ្ម ទោះបីជាមានការអាក្រក់កើតឡើងនៅក្នុងជីវិតយើងច្រើនប៉ុណ្ណាក៏ដោយ។ ព្រះយេស៊ូវអាចធ្វើឱ្យការល្អកើតចេញពីការអាក្រក់ទាំងអស់បាន។

## ៤. ការណែនាំមេរៀន

ថ្ងៃនេះយើងរៀនពីព្រះជាម្ចាស់ដែលទ្រង់តែងធ្វើការអស្ចារ្យនៅក្នុងគ្រប់ស្ថានភាពទាំងអស់។ ប្រសិនបើនៅថ្ងៃនេះប្អូនសប្បាយចិត្ត ហើយអ្វីៗដែលបានកើតឡើងចំពោះប្អូនសុទ្ធតែជារឿងល្អនោះ វាពិតជាអស្ចារ្យណាស់។ ប៉ុន្តែបើនៅថ្ងៃនេះប្អូនៗជួបការលំបាក ហើយមានអារម្មណ៍មិនសប្បាយចិត្ត សូមទុកចិត្តថាព្រះទ្រង់មានអំណាច ហើយទ្រង់អាចធ្វើឱ្យមានការល្អកើតឡើងនៅក្នុងស្ថានភាពអាក្រក់របស់យើង។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

យ៉ាកុបបានរត់ចេញពីផ្ទះឪពុករបស់គាត់ដែលជាអ៊ីសាក បន្ទាប់ពីគាត់បានលួចសិទ្ធិជាកូនច្បងពីបងប្រុសភ្លោះរបស់គាត់គឺអេសាវ។ យ៉ាកុបបានទៅស្រុកម្ដាយគាត់ហើយរស់នៅទីនោះជាមួយនឹងឡាបាន់ដែលត្រូវជាពូរបស់គាត់។ ឡាបាន់មានកូនស្រី ២នាក់ ហើយយ៉ាកុបបានលង់ស្រលាញ់កូនស្រីប្អូនឈ្មោះរ៉ាជែល។ ឡាបាន់ បានប្រាប់យ៉ាកុបថា គាត់អាចរៀបការជាមួយនឹងរ៉ាជែលបាន លុះត្រាតែយ៉ាកុបធ្វើការឱ្យគាត់បាន៧ឆ្នាំ ដោយសារតែយ៉ាកុបស្រឡាញ់រ៉ាជែលខ្លាំង ទើបគាត់យល់ព្រមតាមសំណើររបស់ឡាបាន់។

ប៉ុន្តែបន្ទាប់ពី៧ឆ្នាំកន្លងផុតទៅ ឡាបាន់មិនបានធ្វើតាមការសន្យារបស់គាត់នោះទេ ដោយគាត់បែរជាឱ្យយ៉ាកុបរៀបការនឹងកូនស្រីទី១របស់គាត់គឺលេអាទៅវិញ។ នៅពេលដែលយ៉ាកុបបានដឹងខ្លួនថា គាត់រៀបការជាមួយមនុស្សដែលគាត់មិនបានស្រឡាញ់គាត់មានការខកចិត្តយ៉ាងខ្លាំង។ ឡាបាន់និយាយថាយ៉ាកុបអាចរៀបការជាមួយរ៉ាជែលបាន តែត្រូវធ្វើការឱ្យគាត់៧ឆ្នាំទៀត ។

- តើអ្នកចង់ធ្វើការរយៈពេល១៤ឆ្នាំដើម្បីទទួលបាននូវអ្វីដែលអ្នកចង់បានដោយរបៀបណា?
- តើអ្នកធ្លាប់ត្រូវគេសន្យាថាឱ្យអ្វីមួយហើយទទួលបានអ្វីមួយផ្សេងទៀតដែរឬទេ?
- តើអ្នកមានអារម្មណ៍យ៉ាងណាដែរ?

ប្រហែលជាអ្នកត្រូវខកចិត្ត ឬក៏ខឹងដូចជាយ៉ាកុបផងដែរ។ យ៉ាកុបច្បាស់ជាព្រួយបារម្ភថាឡាបាន់នឹងបោកគាត់ម្ដងទៀតបន្ទាប់ពីធ្វើការឱ្យគាត់អស់១៤ឆ្នាំ។ ប៉ុន្តែយ៉ាកុបបានទទួលយកការអាក្រក់ដែលបានកើតឡើងចំពោះគាត់ ហើយយល់ព្រមធ្វើការឱ្យឡាបាន់៧ឆ្នាំទៀត។

អ្វីដែលយ៉ាកុបគិតថាជារឿងអាក្រក់ ហើយគាត់មានការស្ដាយក្រោយក៏ដោយ តែព្រះបានប្ដូរវាឱ្យទៅជាព្រះពរវិញ! ព្រះបានប្រទានព្រះពរដល់យ៉ាកុបឱ្យមានកូនជាច្រើន គឺកូនប្រុសចំនួន១២នាក់។ កូនៗទាំងអស់របស់គាត់ធំឡើង ហើយមានកូនចៅជាច្រើនបន្តទៀត ហើយព្រះបានប្រើកូនចៅទាំងអស់នោះបង្កើតជាជាតិសាសន៍ដ៏ធំមួយ។ កូនរបស់យ៉ាកុបបានក្លាយទៅជាកុលសម្ព័ន្ធទាំង ១២ របស់អ៊ីស្រាអែល។ កូនចៅរបស់គាត់បានក្លាយជាសាសន៍អ៊ីស្រាអែល! យ៉ាកុបត្រូវរង់ចាំអស់ពេលយ៉ាងយូរ តែគាត់បានដឹងថាព្រះធ្វើការអស្ចារ្យនៅក្នុងគ្រប់ស្ថានភាពទាំងអស់។

**៦. សំនួរពិភាក្សា**

១.ជំនួសឱ្យការគិតថាគ្មានព្រះពិត ឬព្រះមិនស្រឡាញ់កូន ពេលដែលមានការអាក្រក់កើតឡើងចំពោះកូន តើកូនអាចគិតអ្វីពីព្រះ?

*ខ្ញុំអាចគិតថាគ្រប់យ៉ាង ទ្រង់បានធ្វើសំរាប់ខ្ញុំហើយ ខ្ញុំអាចទូលសូម ទ្រង់ឱ្យជួយខ្ញុំឆ្លងកាត់វាផុត*

២. តើកូនបានរៀនអ្វីខ្លះពីស្ថានភាពរបស់យ៉ាកុបដែលអាចជួយកូនបាន?

*ព្រះបានធ្វើការអស្ចារ្យឱ្យ កើតឡើង កូនត្រូវតែអត់ធ្មត់*

**៧. ខគម្ពីរចងចាំ** រ៉ូម ៨:២៨

**៨. ហត្ថកម្ម** ផាត់ពណ៌ រូបយ៉ាកុប និងកូនប្រុសគាត់ទាំង១២

**៩. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១០. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបិទ)*

# យ៉ាកុប និង កូនប្រុសទាំង ១២

